ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ០៨០ សណ១៧ អអក

ភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់លោក ឃុនសេង ប៊ុនហាក់ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបវេល ខេត្តបាត់ដំបង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុកបវេល ខេត្តបាត់ដំបង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោក ឃុនសេង ប៊ុនហាក់ ដើម្បីអនុញ្ញាតឲ្យដកតំបន់ចែកចាយអគ្គិសនីនៅផ្នែកខ្លះនៃឃុំអំពិលប្រាំដើម និងឃុំក្តុលតាហែន ស្រុកបវេល ខេត្តបាត់ដំបង តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងផ្តល់ជូនលោក ឃុនសេង ប៊ុនហាក់ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ..................
..................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងស្រុកបវេល ខេត្តបាត់ដំបង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណលោក ឃុនសេង ប៊ុនហាក់ អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា "**អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ**" ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ឌី និរន្ត**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី៦
## លើឯកសារអាជ្ញាបណ្ណលេខ ១៨២ ឯអ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៧ សម្រាប់លោក ឃុនសេង ប៊ុនហាក់ ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកបវេល ខេត្តបាត់ដំបង

## សម្រាប់ការដកតំបន់ចែកចាយ

## DECISION ON THE SIXTH REVISION

OF THE LICENSE DOCUMENT No.182 LD DATED AUGUST 31, 2007 OF MR. KHUNSENG BUNHAK FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF BAVEL DISTRICT, BATTAMBANG PROVINCE

**FOR WITHDRAWING DISTRIBUTION AREA**

ថ្ងៃទី ខែ ឆ្នាំ២០១៧

… … …, 2017